ទំព័រទី១៖ **ទស្សនាវដ្ដី "និប៉ុនិកា" លេខ៣៥** ស្វែងយល់ពីប្រទេសជប៉ុន

**របាំជប៉ុន**!

ទំព័រទី២៖

ទស្សនាវដ្ដីលេខ៣៥នេះ និយាយអំពី «**របាំជប៉ុន**!»

ប្រទេសជប៉ុនសម្បូណ៍ទៅដោយរបាំប្លែកៗជាច្រើន ដែលនីមួយៗមានភាពទាក់ទាញជាបន្តបន្ទាប់។ គិតចាប់ពីរបាំប្រជាប្រិយក្នុងតំបន់ រហូតដល់របាំប្រពៃណីការសម្ដែងល្ខោនណូ និងការសំដែងលើឆាកដ៏គួរឱ្យភ្ញាក់ផ្អើលដោយតួអង្គអានិមេ(គំនូរជីវចល)។ តស់មកវាំនៅប្រទេសជប៉ុន ដើម្បីឱ្យអ្នកអាចទទួលបានបទពិសោធន៍ដោយផ្ទាល់ពីវប្បធម៌ជប៉ុន។

ទំព័រទី៣៖

មាតិកា

- ហេតុអ្វីបានជាប្រជាជនជប៉ុនរាំ?
- បេតិកភណ្ឌវប្បធម៌អរូបីរបស់ជប៉ុន ហ្វ៊ូរ្យូ អុដូរី
- អ្នករក្សាប្រពៃណី និងអ្នកច្នៃប្រឌិត
- ទៅសាលមហោស្រពដើម្បីមើលការសម្ដែងរបាំ
- របាំក្នុងអានិមេ
- ដំណើរកំសាន្តនិម្មិតទូទាំងប្រទេសជប៉ុន៖ របាំរបាំងមុខរបស់ប្រទេសជប៉ុន
- រសជាតិជប៉ុន៖ ពេលដែលត្រូវទទួលទាន! មីសូមេន
- ដើរកំសាន្តប្រទេសជប៉ុន៖ ហ្គីចូ ហាឈិម៉ាន
- វត្ថុអនុស្សាវរីយ៍របស់ជប៉ុន៖ កានហ្សាស៊ិ

*របាំអាវ៉ា ឬ អាវ៉ាអុដូរី គឺជាសិល្បៈសម្ដែងបែបប្រពៃណីនៅខេត្តតុគូស៊ីម៉ា ដែលប្រារព្ធឡើងរៀងរាល់ឆ្នាំក្នុងខែសីហា ដោយមានអ្នកចូលរួមប្រមាណ១០ម៉ឺននាក់។ (រូបភាព៖ Aflo)*

*រូបភាពលើគម្របៈ អ្នករបាំ ម៉ូរីយ៉ាម៉ា កាអ៊ិឈិ (មើលទំព័រទី១១)*

*រូបភាព៖ អ៊ិសាមូ អ៊ីអ៊ិហារ៉ា(Sun-Ad)*

និប៉ុនិកា ត្រូវបានបោះពុម្ពជាភាសាជប៉ុន និងប្រាំមួយភាសាផ្សេងទៀត រួមមានភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ដើម្បីណែនាំទៅកាន់ពិភពលោកអំពីប្រជាជន និងវប្បធម៌ជប៉ុនសព្វថ្ងៃនេះ។

ចំណងជើងទស្សនាវដ្តី និប៉ុនិកា មានប្រភពមកពីពាក្យ "និប៉ុន" ពាក្យជប៉ុន ដែលមានន័យថា ប្រទេសជប៉ុន។

*ទស្សនាវដ្តីលេខ៣៥* R-051228

*បោះពុម្ពដោយក្រសួងការបរទេសនៃប្រទេសជប៉ុន*

*២-២-១ កាស៊ឹមិហ្គាសិគិ សង្កាត់ជិយ៉ូដា ទីក្រុងតូក្យូ ១០០-៨៩១៩ ប្រទេសជប៉ុន*

*គេហទំព័រផ្លូវការរបស់ក្រសួង* https://www.mofa.go.jp/

<u>ទំព័រទី៤</u>៖

## ហេតុអ្វីបានជាប្រជាជនជប៉ុនរាំ?

នៅតាមសាលមហោស្រព ទីប្រជុំជន និងតាមទីសាធារណៈ...

នៅសាលារៀន នៅផ្ទះ និងនៅលើបណ្តាញសង្គម...

ហេតុអ្វីបានជាប្រជាជនជប៉ុនចូលចិត្តរាំខ្លាំងម្ល៉េះ?

ហេតុផលត្រូវបានលាក់ទុកក្នុងប្រវត្តិសាស្ត្រដ៏យូរលង់។

***កាហ្គ៊ូរ៉ា៖*** *«តាកាឈិហុ ណុ យ៉ុកាហ្គ៊ូរ៉ា (កាហ្គ៊ូរ៉ាពេលរាត្រីនៅតាកាឈិហុ)» មានប្រវត្តិយូរលង់ណាស់មកហើយនៅក្នុងទីក្រុង តាកាឈិហុ នៃខេត្ត មិយ៉ាហ្សាគិ ដែលកាហ្គ៊ូរ៉ាត្រូវបានសម្តែងពេញមួយយប់ថ្វាយជូនដល់កាមិ(អាទិទេព ឬ ព្រះ)។*

***ប៊ូហ្គាគឺ៖*** *ផ្ទាំងគំនូរបង្ហាញពីរបាំប៊ូហ្គាគឺ ដែលត្រូវបានគេស្គាល់ថា«សិអ៊ិកាអ៊ិណាមិ (រលកនៃមហាសមុទ្រពណ៌ខៀវ)» ត្រូវបានសម្តែងនៅព្រះបរមរាជវាំង ប្រហែលសតវត្សរ៍ទី១១។*

*ដកស្រង់ពី សៀវភៅរឿងនិទាន ហ្គេនជិម៉ុណុហ្គាតារីហ្គាចូ(កម្រងសៀវភៅរឿងនិទានហ្គេនជិ) សាលាតូសា៖ ម៉ុមិជិ ណុ ហ្គា (វគ្គរដូវស្លឹកឈើជ្រុះ) នៅផ្នែកខ្លះ។*

*ចងក្រងដោយ៖ សារមន្ទីរទីក្រុងសាកាអ៊ិ*

***របាំកាប៊ូគិ ឬ កាប៊ូគិ អុដូរី៖*** *អុគុនិ ណុ អិហ្សូម៉ុ គឺជាស្ថាបនិកនៃរបាំកាប៊ូគិ ដែលក្នុងចំណោមមនុស្សសាមញ្ញជាច្រើនបានទទួលយកយ៉ាងក្លៀវក្លា។*

*ដកស្រង់ពី អុគុនិ កាប៊ូគិ ហ្ស៊ូ ប្យ៉ូប៊ុ (អេក្រង់អុគុនិ កាប៊ូគិ) នៅផ្នែកខ្លះ។*

*ចងក្រងដោយៈ សារមន្ទីរជាតិក្យូតូ*

វាពិបាកក្នុងការបញ្ជាក់ប្រភពដើមនៃរបាំប្រពៃណីជប៉ុន ប៉ុន្តែគេជឿថា«កាហ្គូរ៉ា» ជាចំណុចចាប់ផ្តើមមួយ។ កាហ្គូរ៉ា បានលេចឡើងជាទម្រង់របាំសាសនាដែលមានបំណងឧទ្ទិសថ្វាយដល់កាមិ(អាទិទេព ឬ ព្រះ)។ នៅអំឡុងសតវត្សរ៍ទី៧ ឧបករណ៍ភ្លេង និងរបាំជាច្រើនត្រូវបានហូរចូលពីបរទេស និងការរួមបញ្ចូលគ្នាជាមួយកាហ្គូរ៉ា បង្កើតបានជា«របាំប៊ូហ្គាគឹ»។ ការរាំរបាំប៊ូហ្គាគឹ អមដោយឧបករណ៍ភ្លេងរួមមានស្យ៉ូ(ស្រដៀងគែន) ហ្វ៊ុអិ(ខ្លុយ) និងតៃកុ(ស្គរ) ហើយត្រូវបានគាំទ្រដោយព្រះបរមរាជវាំង និងអ្នកអភិជន។ ចលនាដែលប្រើក្នុងរបាំប៊ូហ្គាគឹ ដែលអ្នករាំបង្វិលដៃដែលលាតសន្ធឹងយឺតៗ អាចត្រូវបានគេចាត់ទុកថាជាទម្រង់ដើមសម្រាប់ចលនាស្រាល និងទន់ភ្លន់ ដែលក្រោយមកត្រូវបានគេមើលឃើញនៅក្នុងរបាំប្រពៃណីជប៉ុនជាទូទៅ។

ល្ខោនណូ មានដើមកំណើតនៅសតវត្សរ៍ទី១៤ និងមានប្រភពដើមពីរបាំប៊ូហ្គាគឹ ដែលមានទម្រង់មូលដ្ឋានជាបទចម្រៀង និងរបាំ។ ល្ខោនណូ ត្បូងកហៅថា«ស៊ិតិ» បានសម្តែងយ៉ាងឧឡារិករួមជាមួយនឹងតួអង្គផ្សេងទៀត ហើយការសម្តែងអមដោយពាក្យពេចន៍ និងឃុតឆាក ជាទំនុកច្រៀង និងឧបករណ៍តន្ត្រី។ សាលាមួយចំនួនដែលបានអភិវឌ្ឍក្រោមការគាំទ្រដោយអ្នកគ្រប់គ្រងនាពេលនោះ នៅតែបន្តមានសព្វថ្ងៃនេះ ក្រោយពី៦០០ឆ្នាំមកហើយ។ អ្នកបន្តវេននូវភាពស្រស់ស្អាតបែបស្ទីលប្លែកៗជាមួយនឹងរបាំងមុខ សម្លៀកបំពាក់ភ្លឺចែងចាំង និងឆាកដ៏ពិសេស(សូមមើលទំព័រទី១០)។

អំឡុងសតវត្សរ៍ទី១៥ ទម្រង់នៃរបាំមួយដែលមានឈ្មោះថា «ហ្វ៊ូរ្យូ អុដូរី» បានក្លាយជាការពេញនិយមយ៉ាងខ្លាំងក្នុងចំណោមប្រជាជនសាមញ្ញ ដែលត្រូវបានគេនិយាយថាមានដើមកំណើតពីពិធីបុណ្យ និងក្បួនដង្ហែសម្លៀកបំពាក់។ របៀប ឬ ស្ទីលរាំជាក្រុម ដែលក្នុងនោះអ្នកចូលរួមមួយចំនួនធំស្លៀកសម្លៀកបំពាក់យ៉ាងអស្ចារ្យ ហើយរាំរួមគ្នាអមដោយសំឡេងកាណិ(ស្រដៀងគង) និងតៃកុ(ស្គរ) ដែលចាក់ឫសទូទាំងប្រទេសជប៉ុន។ ហ្វ៊ូរ្យូ អុដូរី គឺជាទម្រង់នៃការកម្សាន្តបែបប្រជាប្រិយមួយ ដែលត្រូវបានគេស្គាល់ដោយសារភាពចម្រុះនៃប្រពៃណីក្នុងស្រុកដ៏ប្លែកមួយ (សូមមើលទំព័រ ៦-៩)។

<u>ទំព័រទី៥៖</u>

***បុនអុដូរី ឬ របាំរាំវង់ជប៉ុន៖*** *បុនអុដូរី ដែលអ្នកចូលរួមមិនប្រកាន់វ័យ និងភេទរាំជារង្វង់ជុំវិញ យ៉ាហ្គ៊ូរ៉ា(ប៉ម) គឺជាប្រពៃណីមួយនៃរដូវក្តៅនៅក្នុងប្រទេសជប៉ុន។ រូបភាព៖ Aflo*

***និហុនប៊ូយ៉ូ ឬ របាំប្រពៃណីជប៉ុន៖ «ក្យូកាកុ មឹស៊ឹមុ ដូចូជិ(នាងក្រមុំនៅប្រាសាទដូចូជិ)»*** *ជារឿងល្ខោន បង្ហាញពីអារម្មណ៍ផ្សេងៗរបស់នារីវ័យក្មេងម្នាក់ដែលមានស្នេហា ដោយមានការផ្លាស់ប្តូរសម្លៀកបំពាក់ និងក្បាច់រាំដ៏ស្រស់ស្អាត។ រូបភាពនេះ គឺជា ហ៊្វូជិម៉ា មីរ៉ាសាតិ (ជំនាន់ទី៣) រាំសម្រាប់តំណាងនូវការសម្តែងរបាំជប៉ុន និហុនប៊ូយ៉ូ។ (រូបភាពផ្តល់ដោយ ការិយាល័យហ៊្វូជិម៉ា មីរ៉ាសាតិហា ហ៊្វូជិម៉ារ្យូ)*

***របាំសហសម័យ៖ «ណាត់ស៊ឹបាតាកិ (ការលើកដល់វាលដែលមានពន្លឺថ្ងៃ)»*** *ដោយ DANCE ARCHIVES នៅប្រទេសជប៉ុន ឆ្នាំ២០២៣ ដែលបានបង្ហាញពីរបាំសហសម័យរបស់ជប៉ុន។ ក្បាច់រាំ៖ អុរីតា កាត់ស៊ឹកុ, តួសម្តែង៖ ហ៊ិរ៉ាយ៉ាម៉ា ម៉ុតុកុ, ស៊ិម៉ាជិ យ៉ាស៊ុតាកិ, រូបភាព៖ ស៊ិកាម៉ា តាកាស៊ិ, រូបភាពផ្តល់ដោយ New National Theatre, Tokyo (សាលមហោស្រពជាតិថ្មីនៃទីក្រុងតូក្យូ)*

ហ្វ៊ូរ្យូ អុដូរី ក្រោយមកបានអភិវឌ្ឍទៅជាទម្រង់ពីរផ្សេងគ្នាគឺ «បុនអុដូរី» គឺជារបាំមួយដែលមនុស្សសាមញ្ញអាចចូលរួមរាំដោយសេរី និង «កាប៊ូគិ»ជាការសម្តែងលើឆាកដោយអ្នកសម្តែងអាជីព។

ល្ខោនកាប៊ូគិ មានដើមដើមកំណើតនៅទីក្រុងក្យូតុ ប្រហែលសតវត្សរ៍ទី១៧ នៅពេលការសម្តែងកាប៊ូគិ អុដូរី ដ៏ពេញនិយមត្រូវបានសម្តែងដោយ អ៊ិហ្សូម៉ុ ណុ អុគីនិ ដែលអ្នកសម្តែងស្រីស្លៀកពាក់ជាបុរស ហើយទទួលបានប្រជាប្រិយភាពដោយការបកស្រាយបទចម្រៀងសម័យជាមួយនឹងការសម្តែង។ នៅទីបំផុតតំបន់ប្រជុំជននៃការសម្តែងកាប៊ូគិ បានប្តូរទៅទីក្រុងអេដូ(ទីក្រុងតូក្យូបច្ចុប្បន្ន) ដែលត្រូវបានបង្ហាញទម្រង់ និងក្បាច់រាំពិសេសប្លែកៗ ការផ្លាស់ប្តូរសម្លៀកបំពាក់ភ្លាមៗ និងវិធីសាស្រ្តបង្ហាញនូវអារម្មណ៍ដោយប្រើរបស់តូចៗ ដូចជាអូហ្គិ(ផ្លិតបត់) និងតិនុហ្គុយ(កន្សែងអំបោះ)។ ទន្ទឹមនឹងនោះ នៅក្យូតុ និងអូសាកា «កាមិហ្គាតា ម៉ៃ» បង្កើតចេញពីរបាំកាប៊ូគិ ជាទម្រង់នៃការសម្តែងក្នុងពិធីជប់លៀង។ ប្រពៃណីទាំងនេះបានអភិវឌ្ឍទៅជា«និហុនប៊ូយ៉ូ (របាំប្រពៃណីជប៉ុន)» ដែលសម្តែងនៅសាលមហោស្រព និងពិធីជប់លៀង ហើយមានសាលាសិល្បៈជាង១០០ ដែលអ្នកទាំងនោះជាអ្នកបង្កើតឡើងជាម្ចាស់សិល្បៈនោះដោយផ្ទាល់ ឬ ហៅថា «អ៊ិអិម៉ុតុ»។

សព្វថ្ងៃនេះក្នុងសតវត្សរ៍ទី២១ ល្ខោនណូ និងល្ខោនកាប៊ូគិ ត្រូវបានអង្គការយូណេស្កូទទួលស្គាល់ជាបេតិកភណ្ឌវប្បធម៌អរូបី។ ទន្ទឹមនឹងនេះ អ្នកសម្តែងជនជាតិជប៉ុនជាច្រើនក៏កំពុងសកម្មនៅលើឆាកអន្តរជាតិក្នុងរបៀបផ្សេងៗគ្នា រួមមានរបាំបាឡេ និងរបាំសហសម័យ។ របាំក៏បានក្លាយជាវត្តមានដ៏រីករាយក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជនសាមញ្ញក្នុងប្រទេសជប៉ុន។ ការរាំត្រូវបានដាក់ចូលជាមុខវិជ្ជាដែលចាំបាច់នៅអនុវិទ្យាល័យ ហើយជាទូទៅវាត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៅគ្រប់ប្រភេទផងដែរ។ មនុស្សពេញវ័យរាំដើម្បីបង្ហាញការលើកទឹកចិត្ត ឬ ការគាំទ្ររបស់ពួកគេចំពោះក្រុមកីឡា តារាចម្រៀង និងអ្នកសម្តែងដែលពួកគេពេញចិត្ត។ នៅលើប្រព័ន្ធផ្សព្វផ្សាយ វីដេអូរបស់អ្នករាំស្លៀកពាក់ជាតួអង្គអានិមេ បានជំរុញឱ្យមនុស្សវ័យជំទង់ទៀតបង្ហោះវីដេអូផ្ទាល់ខ្លួនរបស់ពួកគេកាន់តែច្រើនឡើង ដែលបង្កើតឱកាសឱ្យយុវជនរាំរួមគ្នាជាមួយមនុស្សជាច្រើនទៀត។

នៅក្នុងវិធីទាំងអស់នេះ និងលើសពីនេះទៀត ជាច្រើនសតវត្សរ៍មកហើយ ប្រជាជនជប៉ុនបានលើកស្ទួយវប្បធម៌នៃការរាំជាមធ្យោបាយនៃការគាំទ្រចំណងមិត្តភាព។

ទំព័រទី៦៖

## បេតិកភណ្ឌវប្បធម៌អរូបីរបស់ជប៉ុន ហ្វ៊ូរ្យូ អុដូរី

ហ្វ៊ូរ្យូ អុដូរី ត្រូវបានចុះក្នុងបញ្ជីជាបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់យូណេស្កូ ក្នុងឆ្នាំ២០២២។ ពាក្យ «ហ្វ៊ូរ្យូ» ដើមឡើយមានន័យថា ជាអ្វីដែលប្រណិត និងថ្លៃថ្នូរ ប៉ុន្តែនៅទីបំផុតវាសំដៅទៅលើការរាំជាក្រុមដែលសម្តែងដោយមនុស្សមួយក្រុមធំស្លៀកសម្លៀកបំពាក់ដ៏ប្រណិត។ សូមក្រឡេកមើលការរាំដ៏រស់រវើកមួយចំនួនដែលនៅតែសម្តែងនាពេលបច្ចុប្បន្ននេះនៅក្នុងតំបន់នានានៃប្រទេសជប៉ុន។

### បុនអុដូរី នៅនិស៊ិម៉ុណាអ៊ិ (ទីក្រុងអ៊ុហ្គោ ខេត្តអាគិតា)

ក្នុងចំណោមរបាំបុនអុដូរី ដែលត្រូវបានរាំក្នុងពិធីបុណ្យអុបុន(បុណ្យភ្ជុំបិណ្ឌជប៉ុន)ក្នុងខែសីហា នៅពេលដែលវិញ្ញាណរបស់បុព្វបុរស ឬ ជូនតា ត្រឡប់មកវិញនោះ «បុនអុដូរី នៅនិស៊ិម៉ុណាអ៊ិ» ត្រូវបានគេចាត់ទុកថាជារបាំមានភាពឆើតឆាយពិសេសមួយ។ កាយវិការដៃ និងជើងរបស់អ្នករាំ ដែលលាក់មុខរបស់ពួកគេដោយពាក់ អាមិកាសា(មួក) និងហ្សូគីន(ក្រណាត់បិទមុខជិត) ដើម្បីរម្លឹកដល់អ្នកស្លាប់ គឺមានភាពទន់ភ្លន់ និងស្រស់ស្អាត។ សម្លៀកបំពាក់គីម៉ូណុ ដែលត្រូវបានដេរភ្ជាប់ជាមួយនឹងកេនពូ(ក្រណាត់សូត្រ) ហៅថា «ហានុយ» បានបន្ថែមពណ៌កាន់តែទាក់ទាញដល់របាំ។ (រូបភាព៖ PIXTA)

### ស៊ិរ៉ាអ៊ិស៊ិ អុដូរី (ទីក្រុងកាសាអុកា ខេត្តអុកាយ៉ាម៉ា)

របាំប្រពៃណីបុនអុដូរី នៅលើកោះស៊ិរ៉ាអ៊ិស៊ិ ត្រូវបានគេនិយាយថា បានចាប់ផ្តើមឡើងជាពិធីនៃការកាន់ទុក្ខសាមូរ៉ៃដែលបានស្លាប់នៅក្នុងសមរភូមិដែលបានធ្វើឡើងនៅក្នុងសតវត្សរ៍ទី១២។ របាំជាច្រើនប្រភេទត្រូវបានសម្តែងក្នុងពេលដំណាលគ្នាទៅនឹងបទភ្លេងតែមួយដែលគេហៅថា«គឺដូគិ»។ សព្វថ្ងៃនេះ របាំ១៣ប្រភេទ ត្រូវបានគេស្គាល់។ ភាពរីករាយដែលបង្កើតឡើងដោយរបាំជាច្រើនជាមួយនឹងសម្លៀកបំពាក់ និងកាយវិការផ្សេងៗគ្នា គឺពិតជាអស្ចារ្យណាស់។ (រូបភាព៖ សាលាក្រុងកាសាអុកា)

### បុនអុដូរី នៅកិម៉ាណាអ៊ិ (ទីក្រុងកាហ្ស៊ូណូ ខេត្តអាគិតា)

នៅក្នុងរបាំបុនអុដូរី ដែលមានចលនាយ៉ាងសម្បូណ៌បែបមួយនេះ អ្នករបាំបញ្ចេញកាយវិការយ៉ាងទន់ភ្លន់នៅជុំវិញភ្លើង ដោយដៃរបស់ពួកគេលាតបោះដល់ចុងម្រាមដៃ។ ទាំងបុរស និងស្ត្រីស្លៀកឈុតគីម៉ូណុផ្លូវការដែលមានពណ៌ខ្មៅ ហើយគ្របមុខរបស់ពួកគេដោយកន្សែងតិនុហ្គុយដែលមានក្រឡារូបពងជីងចក់។ (រូបភាព៖ Aflo)

ទំព័រទី៧៖

## យ៉ាស៊ូរ៉ៃបាណា (ទីក្រុងក្យូតុ ខេត្តក្យូតុ)

ព្រឹត្តិការណ៍នេះត្រូវបានប្រារព្ធឡើងនៅបួនកន្លែងនៅក្នុងទីក្រុងក្យូតុគឺ អ៊ិម៉ាមិយ៉ា កាវ៉ាកាមិ ហ្គេនប៊ុ និងកាមិហ្គាម៉ុ នៅនិទាឃរដូវ នៅពេលដែលផ្កាសាគូរ៉ារីក ដើម្បីជាការបួងសួងសម្រាប់បណ្តេញវិញ្ញាណអាក្រក់ និងជំងឺរាតត្បាតដែលនាំមកនូវគ្រោះមហន្តរាយ។ អ្នកសម្តែងស្លៀកពាក់ជាតួបិសាចដែលមានសក់ពណ៌ក្រហម ឬ ខ្មៅ ហៅថា «ស្យ៉ាហ្គុម៉ា» ដោយវាយកាណិ(ស្រដៀងគង) និងតៃកុ(ស្គរ) អមជាមួយចម្រៀងបទ «យ៉ាស៊ូរ៉ៃបាណាយ៉ា» និងសំឡេងហ្វ៊ូអិ(ខ្លុយ)។ រូបភាពបង្ហាញពីស្ថានភាពនៅតំបន់អ៊ិម៉ាមិយ៉ា។ (រូបភាព៖ Aflo)

## នេនប៊ុត្ស៊ឹ អុដូរី នៅតាគិណុមិយ៉ា (ទីក្រុងអាយ៉ាហ្គាវ៉ា ខេត្តខាហ្គាវ៉ា)

ជារៀងរាល់ឆ្នាំនៅចុងខែសីហា ការរាំនេះត្រូវបានប្រារព្ធឡើងនៅព្រះវិហារតាគិណុមិយ៉ា និងទីសក្ការបូជា តាគិណុមិយ៉ា តេនម៉ានហ្គូ ដើម្បីសម្តែងការដឹងគុណដល់ ស៊ូហ្គាវ៉ារ៉ា មិឈិហ្សាណិ ដែលជាកវី និងអ្នកនយោបាយ ដែលបានជួយសង្គ្រោះមនុស្សជាច្រើនពីគ្រោះរាំងស្ងួតដ៏ធ្ងន់ធ្ងរក្នុងអំឡុងពេលសម័យហេអាន និងដើម្បីបួងសួងសុំទឹកភ្លៀង និងការប្រមូលផលដ៏បរិបូរណ៍។ អ្នករបាំដែលកាន់ផ្លិតអូហ្គិវ៉ា បានហៅថា«ហ្គេនជិ» រាំតាមតន្ត្រីបទ«ណាមុ អាមិ ដុយ៉ា» លេងដោយតៃកុ(ស្គរ) ហ្វ៊ូអិ(ខ្លុយ) កាណិ (ស្រដៀងគង) និង ហុរ៉ាហ្គៃ(សំបកខ្យងស័ង្ខ)។ (រូបភាព៖ ទីក្រុងអាយ៉ាហ្គាវ៉ា)

## អាយ៉ាកុម៉ៃ (ទីក្រុងកាស៊ិវ៉ាហ្សាគិ ខេត្តនីហ្គាតា)

សិល្បៈសម្តែងនេះមានរយៈពេលប្រហែល៥០០ឆ្នាំមកហើយ និងត្រូវបានបន្តដោយសាលមហោស្រពចំនួនពីរគឺ សាលមហោស្រពតាកាណាដា និង ស៊ិម៉ុណុ។ វាមានបីផ្នែកគឺ កុតាអុដូរី រាំដោយស្ត្រី, ហាយ៉ាស៊ី-ម៉ៃ និង ក្យូហ្គេន រាំដោយបុរស។ កុតាអុដូរី គឺជាការរាំដ៏គួរឱ្យទាក់ទាញដែលអ្នករបាំស្រីមានពាក់ក្រណាត់ក្រហម ហៅថា «យូរ៉ៃ» លើក្បាលរបស់នាង ហើយរាំដោយចលនាជើងដើរយ៉ាងប្រណិត និងដៃកាន់ផ្លិតអូហ្គិយ៉ាងទន់ភ្លន់។ (រូបភាព៖ តាកាហាស៊ិ ម៉ាសាហ៊ិតុ /បណ្ណាល័យហាហ្គា)

ទំព័រទី៨៖

## កាណុមិហ្ស៊ឹ កាកេអុដូរី (ទីក្រុងហ្គិចូ ខេត្តហ្គីហ្វ៊ូ)

របាំនេះត្រូវបានសម្តែងនៅក្នុងពិធីបុណ្យប្រចាំឆ្នាំមួយដែលត្រូវបានប្រារព្ធឡើងជាបន្តបន្ទាប់អស់រយៈពេលជាង៣០០ឆ្នាំមកហើយ នៅព្រះវិហារហាគុសាន ក្នុងតំបន់កាណុមិហ្ស៊ឹ។ ពួកគេរាំជារង្វង់ ជាមួយនឹងការតុបតែងផ្កាឫស្សី ហៅថា «ស៊ីណៃ» នៅលើខ្នងរបស់ពួកគេ ដោយវាយតៃកុ (ស្គរ) និងកាណិ(ស្រដៀងគង)។ អ្នករាំស្លៀកសម្លៀកបំពាក់ប្លែកៗផ្សេងៗគ្នា ដូចជាពាក់របាំងមុខ និងហាណាហ្គាសា(មួកផ្កា)ជាដើម។ (រូបភាព៖ សហព័ន្ធទេសចរណ៍ទីក្រុងហ្គិចូ)

**ចាកគិរ៉ាកុ ( ទីក្រុងមិអ៊ុរ៉ា ខេត្តកាណាហ្គាវ៉ា )**

របាំនេះប្រារព្ធធ្វើនៅព្រះវិហារកៃណាន នៅថ្ងៃទី១៥ នៅពេលចូលឆ្នាំថ្មី ដើម្បីបួងសួងសូមឱ្យមានលាភសំណាងក្នុងការប្រកបរបរនេសាទ និងជំនួញជាដើម។ «ចាកគិរ៉ាកុ» គឺជាក្មេងស្រីស្លៀកពាក់គីម៉ូណូពណ៌ក្រហមរាំជាមួយ អាយ៉ាតាកិ ២ ( ដំបងឫស្សីដែលមានកណ្ដឹង និងការតុបតែង ) និងផ្លិតអូហ្គិ អមដោយការច្រៀងរបស់ស្ត្រីចំណាស់។ ( រូបភាព៖ Aflo )

**យ៉ុសុិហ៊ិរ៉ុ ហ្គាគឺ ( ទីក្រុងគីនិសាតិ ខេត្តអុអ៊ិតា )**

ការសម្ដែងរបាំនេះធ្វើឡើងរៀងរាល់ឆ្នាំក្នុងខែកក្កដា នៅព្រះវិហារ ហ្គាគឺនិវ៉ា ហាឈិម៉ាន ដើម្បីបួងសួងសូមឱ្យបញ្ចៀសសត្វល្អិតពីការបំផ្លិចបំផ្លាញដំណាំកសិកម្ម។ តន្ត្រីករពាក់ កុសុិមិណុ( អាវក្លៀងចំបើង ) នៅជុំវិញចង្កេះរបស់ពួកគេ និងពាក់ កាប៊ូតុ( មួកអ្នកចម្បាំងសាម៉ូរ៉ៃ ) នៅលើក្បាលរបស់ពួកគេ សម្ដែងរបាំយ៉ាងរស់រវើក។ ( រូបភាព៖ ទីក្រុងគីនិសាតិ )

<u>ទំព័រទី៩</u>៖

## ឧបករណ៍ភ្លេងបន្ថែមក្នុងរបាំ

ឧបករណ៍តន្ត្រី លេងជាចង្វាក់ និងមេរ៉ូឌីភ្លេងត្រូវបានប្រើជាឧបករណ៍ភ្លេងសម្រាប់ក្បាច់រាំ ដើម្បីបន្ថែមភាពទាក់ទាញ និងធ្វើឱ្យកាន់តែរស់រវើកនៃរបាំប្រជាប្រិយជប៉ុន ហ្វ៊ូរ្យូ អុដូរី។

*កិច្ចសហប្រតិបត្តិការ៖ Miyamoto Unosuke Co., Ltd.*

**អាយ៉ាតាកិ ( ដំបងឫស្សីដែលមានកណ្ដឹង និងការតុបតែង )**

អ្នករាំកាន់ដំបងឫស្សីទាំងនេះ ដែលមានការតុបតែងដោយក្រដាសពណ៌ និងកណ្ដឹង កាន់ក្នុងដៃទាំងសងខាង បង្វិលវា និងគោះវានៅពេលរាំ។ រូបភាព អាយ៉ាតាកិ បង្ហាញនៅទីនេះ ត្រូវបានប្រើក្នុងរបាំចាកគិរ៉ាកុ។ ( រូបភាព៖ ទីក្រុង មិអ៊ុរ៉ា )

**ហ្វ៊ូអិ ( ខ្លុយ )**

ជារឿយៗនៅក្នុងរបាំប្រជាប្រិយជប៉ុន ហ្វ៊ូរ្យូ អុដូរី តែងតែលេចឡើងនូវ ខ្លុយឫស្សី យ៉ុកុហ្វ៊ូអិ និងសុិណុប៊ូអិ។ ភ្លេងសំខាន់នៃតន្ត្រីដែលអមជាមួយការរាំទាំងនេះបានមកពីសំឡេងច្បាស់ និងខ្ពស់នៃហ្វ៊ូអិ( ខ្លុយ )។

**តៃកុ( ស្គរ )**

តៃកុ គឺជាស្គរ ដែលលេងដោយ បាឈិ( ដំបងឈើ )។ អ្នករាំ យ៉ាស៊ូរ៉ាអុិ បាណា និង យ៉ុសុិហ៊ិរ៉ុ ហ្គាគឺ ពួកគេរាំបណ្ដើរ និងវាយស្គរសុិម៉ិដៃកុ( ក្នុងរូប ) ដែលមានរូបរាងតូច និងសំឡេងខ្ពស់។

## អូហ៊្គិ(ផ្លិតបត់)

ផ្លិតអូហ៊្គិ មិនត្រឹមតែមានប្រយោជន៍សម្រាប់បក់ធ្វើឱ្យត្រជាក់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាឧបករណ៍ចាំបាច់សម្រាប់របាំ និងពិធីបុណ្យរបស់ជប៉ុនផងដែរ។ វាត្រូវបានប្រើក្នុងវិធីជាច្រើនដូចជា បើកលាតសន្ធឹង ឬ លើកវាឡើងខ្ពស់ ឬ ធ្វើវាឱ្យយោលយោគតាមខ្យល់ដូចក្នុងចលនារលកជាដើម។ រូបភាពនេះបង្ហាញពីផ្លិតអូហ៊្គិដែលប្រើនៅក្នុងរបាំចាកគិ៉កុ។ (រូបភាព៖ ទីក្រុងមិអ៊ី៉)

## អ៊ុឈិវ៉ា(ផ្លិតលាត)

ដូចផ្លិតអូហ៊្គិ ដែរ គឺប្រើដើម្បីបក់ឱ្យរហើយ និងដើរតួយ៉ាងសំខាន់ក្នុងរបាំផងដែរ។ យោលយោគ រវាំ និងទះដៃតាមចង្វាក់ភ្លេងបានបន្ថែមភាពអស្ចារ្យដល់ការរាំ។ រូបភាពផ្លិតអ៊ុឈិវ៉ាធំនេះ ប្រើនៅក្នុងនេនប៊ុត្សឺ អ៊ុដូរី នៅតាគិណុមិយ៉ា។ (រូបភាព៖ ទីក្រុងអាយ៉ាហ្គាវ៉ា)

## កាណិ(ស្រដៀងគង)

កាណិ រាងមូលដូចឌីស ធ្វើឡើងពីទង់ដែង និងលោហធាតុផ្សេងទៀត ហើយត្រូវបានវាយដោយ «បាឈិ» ដែលជាដំបងរាងតូចមួយ ដើម្បីបង្កើតចង្វាក់។ កាណិ ត្រូវបានប្រើនៅក្នុងរបាំប្រជាប្រិយ ហ្វ៊ូរ្យូ អ៊ុដូរី របស់ជប៉ុនស្ទើរតែទាំងអស់។ វាមានសំឡេងខ្ពស់ និងមុត។

<u>ទំព័រទី១០</u>៖

## អ្នករក្សាប្រពៃណី និងអ្នកច្នៃប្រឌិត

*រូបភាព៖ គុរីហារ៉ា អ៊ុសាមឺ*

***កានហ្សិ សាប៊ុរ៉ុតា***

*លោក សាប៊ុរ៉ុតា ពាក់ម៉ាសមុខ ហើយសម្តែងក្នុងបទ «អ៊ុគិណា(បុរសចំណាស់)» ប្រកបដោយភាពថ្លៃថ្នូរអស្ចារ្យ។*

*លោក សាប៊ុរ៉ុតា ឈរដាក់កម្លាំងនៅត្រគាក ទាញចង្កាចូលក្នុង ដែលវាជាកាយវិការមូលដ្ឋានរបស់ល្ខោនណូ ហៅថា«កាម៉ាអិ»។*

## រាំជាមួយអារម្មណ៍នៃការបួងសួង

«ណូ» គឺជាល្ខោនប្រពៃណីដែលមានអាយុកាលចំណាស់ជាងគេបំផុតរបស់ពិភពលោកដែលមានទាំងចម្រៀង និងរបាំ ដោយអ្នកសម្តែងធ្វើចលនាយឺតៗ ដូចជាពេលឡើងឆាក អមដោយ ហ្វ៊ុអិ(ខ្លុយ) កុត្សឹហ្សឹមិ(ស្គរតូច) អូត្សឹហ្សឹមិ(ស្គរធំ) និងតៃកុ(ស្គរ) ព្រមជាមួយការច្រៀងជាទម្រង់កំណាព្យ។ ល្ខោនណូនេះមានកំណើតនៅសតវត្សរ៍ទី១៤ ហើយបន្តឱ្យមនុស្សជំនាន់ក្រោយរហូតដល់បច្ចុប្បន្ននូវក្បាច់ និងទម្រង់។

តួសម្តែងវ័យក្មេងម្នាក់ក្នុងចំណោមតួសម្តែងល្ខោនណូដ៏ឆ្នើមបំផុតក្នុងការបន្តប្រពៃណីនេះគឺ លោក កានហ្សិ សាប៊ុរ៉ុតា។ ឪពុករបស់លោកឈ្មោះ កានហ្សិ គិយ៉ុកាហ្សុ គឺជាប្រធានទី២៦ នៃសាលាកានហ្សិ ដែលមានបុព្វបុរសគឺ កាន អាមិ និង ហ្សិ អាមិ ដែលជាស្ថាបនិកនៃល្ខោនណូ។

«ខ្ញុំហាត់ជាមួយគ្រូរបស់ខ្ញុំ(ឪពុកខ្ញុំ)ជារៀងរាល់ថ្ងៃ។ ខ្ញុំមើល និងរៀនចលនានីមួយៗ ហើយយកតម្រាប់តាម ម្តងហើយម្តងទៀត»។

លោក សាប៊ុរ៉ុតា បានចាប់ផ្តើមសម្តែងលើឆាកដំបូងនៅអាយុ៥ឆ្នាំ ហើយដើរតួជា ស៊ិតិ(តួឯក) ជាលើកដំបូងនៅអាយុ១០ឆ្នាំ និងសម្តែងជាតួ ហាត៊ីអុម៉ុតិ ជាលើកដំបូងជាមួយនឹងរបាំងមុខ នៅអាយុ១៦ឆ្នាំ។ ក្រោមការណែនាំពីឪពុក លោកបានបន្តរីកចម្រើន ហើយនៅឆ្នាំ២០២២ នៅអាយុ២៣ឆ្នាំ លោកបានសម្តែងជា ស៊ិតិ(តួឯក)ក្នុងរឿងអុគិណា ជារឿងបុរាណដែលសម្តែងប្រចាំសាលាកានហ្សិ។

រឿងអុគិណា ត្រូវបានគេនិយាយថាជារឿងពិសេសមួយក្នុងចំណោមរឿងល្ខោនណូទាំងអស់។ រឿងនេះ មិនមានសាច់រឿងទេ វាដូចជាពិធីបួងសួងដ៏ពិសិដ្ឋដែលអ្នកសម្តែងរាំថ្វាយដល់កាមិ(អាទិទេព ឬ ព្រះ)។ អ្នកសម្តែងដើរតួជាអាទិទេព ឬ ព្រះ ហើយរាំយ៉ាងឱឡារិកបួងសួងសូមសេចក្តីសុខនាពេលអនាគត និងការរម្លឹកដល់អ្នកដែលបានចែកឋាន។

«ប្រសិនបើអារម្មណ៍នៃការបួងសួងមិនកើតចេញពីខាងក្នុងនោះទេ ការរាំក៏នឹងមិនល្អដែរ។ ដោយសារហេតុផលនេះ ខ្ញុំទទួលបានការបង្រៀនមកថា វាជារឿងសំខាន់ដែលយើងត្រូវមានអាកប្បកិរិយាត្រឹមត្រូវក្នុងជីវិតប្រចាំថ្ងៃផងដែរ»។

ខណៈពេលដែលកំពុងខិតខំប្រឹងប្រែងដើម្បីបន្តសិល្បៈប្រពៃណីរបស់ជប៉ុន ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ លោក សាប៊ុរ៉ុតា ក៏បានសាកល្បងបង្កើតការសម្តែងល្ខោនណូថ្មីជាមួយនឹងទម្រង់សម័យបច្ចុប្បន្ន។ លោកនិយាយថា លោកមានបំណងបង្កើតឱកាសសម្រាប់អ្នកដែលមិនស្គាល់សិល្បៈសម្តែងបុរាណជប៉ុន បានស្វែងយល់ពីភាពគួរឱ្យចាប់អារម្មណ៍របស់ល្ខោនណូ។

«មនុស្សជាច្រើនប្រហែលជាពិបាកយល់ពីល្ខោនណូ ដែលមានតែពាក្យ និងកាយវិការមួយចំនួនប៉ុណ្ណោះ។ ប៉ុន្តែការរំភើបចិត្តពិតប្រាកដរបស់ល្ខោនណូ គឺការរីករាយជាមួយនឹងសមត្ថភាពនៃការស្រមើស្រមៃរបស់អ្នក និងការបកស្រាយវាតាមវិធីរបស់អ្នកផ្ទាល់។»

ទំព័រទី១១៖

អ្នកសម្តែងល្ខោនណូ វ៉ៃក្មេងម្នាក់ដែលទទួលមរតកប្រវត្តិសាស្ត្រ៦០០ឆ្នាំ និងជាអ្នករាំដែលស្វែងយល់ពីការបង្ហាញចេញនូវអ្វីថ្មីៗដោយផ្អែកលើទម្រង់បុរាណ។ ឆ្លងកាត់សម័យកាលជាច្រើន វប្បធម៌ជប៉ុនទាំងចាស់ និងថ្មីបានរីកដុះដាលនៅលើឆាករបាំ។

*ម៉ុរីយ៉ាម៉ា កាអ៊ិឈិ*

## ការបង្ហាញរបាំរវាងវត្តមាន និងអវត្តមាន

ម៉ុរីយ៉ាម៉ា កាអ៊ិឈិ គឺជាអ្នករបាំឈានមុខគេម្នាក់ក្នុងវិស័យរបាំសហសម័យ។ លោកទាក់ទាញអ្នកទស្សនាជាមួយនឹងភាពអស្ចារ្យនៃក្បាច់រាំរបស់លោកដែលរួមបញ្ចូលគ្នានូវចលនាកោង ជាមួយនឹងចលនាលីនេអ៊ែរ (ចលនាដែលមានល្បឿនថេរ និងត្រង់) ដែលហាក់ដូចជាការកាត់ដាច់ចេញពីលំហ។

«ខ្ញុំតែងតែធ្វើចលនាបែបនៅក្នុងលំហ ដែលធ្វើឱ្យខ្ញុំមានអារម្មណ៍ថាខ្ញុំកំពុងអណ្តែត។ នេះគឺដើម្បីបង្ហាញពីភាពស្រាល ហើយប្រសិនបើអាចធ្វើទៅបាន ខ្ញុំចង់លុបបំបាត់សូម្បីតែវត្តមានរបស់ខ្ញុំផងដែរ។ ជាយូរមកហើយ ខ្ញុំរាំតាមអារម្មណ៍បែបនេះ។»

«យឺត្សឺរី(សត្វក្រៀលពេលរាត្រី)» ត្រូវបានបង្ហាញក្នុងឆ្នាំ២០០១ជាលទ្ធផលនៃការបន្តអារម្មណ៍បែបចង់លុបបំបាត់វត្តមានរបស់ខ្លួន។ របាំនេះផ្អែកលើរឿងនិទានប្រជាប្រិយជប៉ុន«ត្សឺរី ណុ អុនហ្គាអិស៊ុ(ការសងគុណរបស់សត្វក្រៀល)» ដែលសត្វក្រៀលបានកាឡាខ្លួនទៅជាមនុស្សដើម្បីមកសងគុណដល់គូស្នេហ៍វ៉ៃចំណាស់។ តើតួសម្តែងនោះ ជាសត្វស្លាប ឬ ជាមនុស្ស ឬ មិនមែនជាអ្វីលើពិភពលោកនេះ? តាមរយៈការរាំក្នុងរឿងជាមួយនឹងទិដ្ឋភាពមិនច្បាស់លាស់ លោកម៉ុរីយ៉ាម៉ា បានព្យាយាមបង្ហាញគោលបំណងអំពីភាពដែលអវត្តមាន។ ចាប់តាំងពីពេលនោះមក លោកនិយាយថា «″ការបង្ហាញរវាងវត្តមាន និងអវត្តមាន″ បានក្លាយជាប្រធានបទរបស់ខ្ញុំ»។

ចាប់តាំងពីពេលនោះមក លោកបានបន្តបង្កើតឆាកសម្តែងដោយផ្អែកលើប្រធានបទវប្បធម៌ជប៉ុនជាច្រើនដូចជា«កាតាណា» ដែលបង្ហាញពីដាវជប៉ុនដ៏មុតស្រួច និង«និនចា» បញ្ចូលទៅក្នុងរបាំដែលពោរពេញដោយភាពកំប្លុកកំប្លែង។

«ខ្ញុំចង់អភិវឌ្ឍកាយវិការបែបជប៉ុនដ៏ពិសេសមួយ នៅពេលពណ៌នាអំពីអ្វីដែលពិបាកមើលឃើញនឹងភ្នែកផ្ទាល់ ដូចជាវិញ្ញាណដែលបានបង្កប់នៅក្នុងដាវ និងចលនារបស់និនចា ប្រើដើម្បីលាក់វត្តមានរបស់ពួកគេ។»

*រូបខាងលើ៖ «កាតាណា» បង្ហាញពីភាពមុតស្រួចនៃដាវជប៉ុន តាមរយៈរាងកាយដែលបានហ្វឹកហាត់យ៉ាងម៉ឺងម៉ាត់។ រូបថត៖ យ៉ុស៊ិកាហ្ស៊ឺ អ៊ិណុអ៊ុអិ*

*រូបកណ្តាល៖ «និនចា» បង្ហាញរូបភាពរបស់និនចាក្នុងចលនាកាយវិការកំប្លែង។ រូបថត៖ ស៊ិកាម៉ា តាកាស៊ិ*

*រូបភាពផ្តល់ដោយ៖ សាលមហោស្រពជាតិថ្មី, តូក្យូ*

*រូបខាងក្រោម៖ លោក ម៉ុរីយ៉ាម៉ានិយាយថា «ខ្ញុំចង់ឱ្យរាងកាយរបស់ខ្ញុំបន្តអាចផ្លាស់ប្តូរបានទាំងអស់តាមតែខ្ញុំចង់បាន ឱ្យទៅជាមានវត្តមាន។» រូបភាព៖ Studio ARCHITANZ*

ទំព័រទី១២៖

## ទៅសាលមហោស្រពដើម្បីមើលការសម្តែងរបាំ

### របាំថ្មី ពីនីហ្គាតា ទៅកាន់ពិភពលោក

### ក្រុមរបាំ ណយហ្ស៊ឹម ខមផេនី នីហ្គាតា (Noism Company Niigata)

Noism Company Niigata គឺជាក្រុមរបាំដំបូងគេរបស់ប្រទេសជប៉ុនដែលធ្វើការសម្តែងសម្រាប់សាលមហោស្រពសាធារណៈ ដែលមានទីតាំងនៅមជ្ឈមណ្ឌលសិល្បៈ និងវប្បធម៌ទីក្រុងនីហ្គាតា (Ryutopia)។ ក្រុមនេះត្រូវបានដឹកនាំដោយ លោក កាណាម៉ុរី ចូ ដែលជាអ្នករបាំ និងអ្នកសម្តែងដែលមានការទទួលស្គាល់ពីពិភពលោក ដោយលោកបន្ត និងផ្សព្វផ្សាយក្បាច់រាំប្លែកៗ តាមរយៈការបណ្តុះបណ្តាលដែលរួមបញ្ចូលគ្នានូវបច្ចេកទេសសិល្បៈរាងកាយភាគខាងកើត និងលោកខាងលិច។ អ្នករបាំវ័យក្មេងដែលត្រូវបានជ្រើសរើសមកពីជុំវិញពិភពលោក មានមូលដ្ឋាននៅទីក្រុងនីហ្គាតា ជាកន្លែងដែលពួកគេបង្កើតសិល្បៈសម្តែងដោយអាចចែករំលែកជាមួយពិភពលោក ក៏ដូចជាចូលរួមក្នុងសកម្មភាពសហគមន៍សម្រាប់ប្រជាពលរដ្ឋក្នុងតំបន់ផងដែរ។

*រូបខាងលើ៖ «អុនិ(យក្ខ ឬ បិសាច)»រាំយ៉ាងស្វាហាប់ជាមួយការសម្តែងរបស់ក្រុមតន្ត្រីវាយស្គរ តែកុ កុដុ។ (រូបភាព៖ ស៊ីនណុយ៉ាម៉ា គិស៊ីន)*

*រូបខាងស្តាំ៖ មជ្ឈមណ្ឌលសិល្បៈ និងវប្បធម៌ទីក្រុងនីហ្គាតា ត្រូវបានរចនាឡើងមើលទៅហាក់ដូចជាអណ្តែតលើទឹក។*

ទំព័រទី១៣៖

របាំប្រពៃណីជប៉ុន របាំទំនើប និងរបាំតួអង្គតុក្កតា។ តស់ទៅទស្សនាការសម្តែងរបាំគ្រប់ប្រភេទ!

### តស់រាំជាមួយតួអង្គតុក្កតា

### សួនកម្សាន្ត សានរីអ៊ូ ពូរ៉ូឡែន(Sanrio Puroland)

ប្រសិនបើអ្នកធ្លាប់ស្រមៃចង់ឃើញ ហេឡូឃីតធី(Hello Kitty) និងតួអង្គសានរីអ៊ូ(Sanrio)ផ្សេងទៀត ដែលច្រៀង និងរាំនៅជិតខ្លួនអ្នកនោះ អ្នកអាចធ្វើឱ្យសុបិនរបស់អ្នកក្លាយជាការពិតដោយទៅទស្សនា សានរីអ៊ូ ពូរ៉ូឡែន (San rio Puroland) ដែលជាសួនកម្សាន្ត។ ការចូលរួមក្នុងក្បួនដង្ហែអមដោយតន្ត្រីប៉ុប និងការរាំដោយគ្រវីបិចពិលជាមួយនឹងតួអង្គដែលអ្នកចូលចិត្តនោះ នឹងធ្វើឱ្យអ្នកដូចនៅក្នុងពិភពសានរីអ៊ូ។

*រូបខាងលើ៖ «Miracle Gift Parade(ក្បួនដង្ហែកាដូដ៏អស្ចារ្យ)» ដែលជាកន្លែងដែលអ្នកអាចរីករាយជាមួយការរាំរបស់តួអង្គសំខាន់ៗរបស់សានរីអូ(Sanrio)។*

*រូបខាងឆ្វេង៖ ច្រកចូលសួនកម្សាន្ត សានរីអូ ពូរ៉ូឡែន(Sanrio Puroland) ដែលនាំអ្នកទៅកាន់ពិភពនៃរឿងនិទាន។*

*©1990, 2023 SANRIO CO., LTD. តូក្យូ, រក្សាសិទ្ធិដោយ Sanrio Co., Ltd.*

<u>ទំព័រទី១៤</u>៖

## អុសុិ ណុ កុ (កូនសំណព្វ)

គំនូរជីវចលនេះពណ៌នាអំពីការពិតនៃឧស្សាហកម្មកម្សាន្ត និងពិភពនៃតារាចម្រៀងអាយដូល(ជាក្រុម) ដោយផ្តោតលើរឿងរបស់អាយដូលដ៏ឆ្នើម(បង្ហាញក្នុងរូបភាព) និងកូនៗរបស់នាង។ នៅក្នុងខ្សែភាពយន្តនេះ អាយដូល និងតារាផ្សេងទៀតតែងតែច្រៀង និងរាំ ហើយអ្នកគាំទ្រវ័យក្មេងជាច្រើនបានធ្វើត្រាប់តាមពួកគេ ហើយបង្ហោះវីដេអូនៅលើបណ្តាញសង្គម។

*©Akasaka Aka x Yokoyari Mengo /*

*SHUEISHA Inc. / Oshi no Ko Production Committee (គណកម្មការផលិតរឿង អុសុិ ណុ កុ)*

## របាំក្នុងអានិមេ

តួអង្គក្នុងគំនូរជីវចល ឬ អានិមេ ជប៉ុនតែងតែរាំ។ ជាពិសេសក្នុងអំឡុងពេលបើក និងបញ្ចប់រឿង ដោយតួអង្គបានបង្ហាញនូវមនោសញ្ចេតនាខុសគ្នា ដែលពេលខ្លះគួរឱ្យស្រឡាញ់ និងជួនកាលរាំយ៉ាងស្វាហាប់។

*©Takamatsu Misaki / Kodansha Ltd. / Sukippu to Rofa Production Committee (គណកម្មការផលិតរឿង ស៊ុគីបពុ តុ រ៉ូហ្វា)*

## រឿង ស៊ីគីបពុ តុ រ៉ូហ្វា (លោតរំលង និងក្មេងអនាថា)

រឿងនេះពណ៌នាពីជីវិតសិក្សារបស់សិស្សវិទ្យាល័យ ដោយផ្តោតលើទំនាក់ទំនងរវាងតួឯក អ៊ីវ៉ាគុរ៉ា មិត្សឹមិ ដែលបានផ្លាស់ពីជនបទមកនៅទីក្រុងតូក្យូ និងមិត្តភក្តិរបស់នាង។ ឈុតបើកឆាកដែល មិត្សឹមិ និងមិត្តរួមថ្នាក់របស់នាង ស៊ិម៉ា សុស៊ុកិ រាំលោតរំលង គឺពោរពេញដោយបរិយាកាសទន់ភ្លន់ ដែលធ្វើឱ្យអ្នកទស្សនាមានអារម្មណ៍កក់ក្តៅ។

*©Takamatsu Misaki / Kodansha Ltd. / Sukippu to Rofa Production Committee (គណកម្មការផលិតរឿង ស៊ុគីបពូ តុ រ៉ូហ្វា)*

ទំព័រទី១៥៖

## រឿង សុរ៉ិអ៊ិកិ! អានប៉ុងម៉ាន (តស៊ូទៅ! វីរបុរសអានប៉ុងម៉ាន)

រឿងភាគនេះត្រូវបានកុមារជាច្រើនស្រឡាញ់មកជាច្រើនឆ្នាំហើយចាប់តាំងពីវាបានចាប់ផ្តើមចាក់ផ្សាយក្នុងឆ្នាំ១៩៨៨។ សាច់រឿងបង្ហាញពីសារៈសំខាន់នៃភាពក្លាហាន និងមិត្តភាពតាមរយៈវគ្គដែលពាក់ព័ន្ធនឹង អានប៉ុងម៉ាន ដែលជាវីរបុរស និងជានិមិត្តរូបនៃយុត្តិធម៌ និងមិត្តភក្តិ។ បទចម្រៀងបញ្ចប់មានដូចជា«អានប៉ុងម៉ាន តៃសូ(លំហាត់ប្រាណវីរបុរសអានប៉ុងម៉ាន)» និង«សានសាន តៃសូ(លំហាត់ប្រាណព្រះអាទិត្យ)» គឺជាក្បាច់រាំដែលរួមបញ្ចូលចលនារាងកាយទាំងមូល និងងាយស្រួលសម្រាប់កុមារចងចាំ។ ក្បាច់រាំនេះ ត្រូវបានសម្តែងជាញឹកញាប់នៅថ្ងៃមាតាបិតានៅសាលា និងព្រឹត្តិការណ៍នានាសម្រាប់កុមារ។

*©Yanase Takashi / FROEBEL-KAN CO., LTD. / TMS / NTV*

## រឿង ស៊ុហ្ស៊ឹមិយ៉ា ហារុហិ ណុ យ៉ុអ៊ុត្ស៊ឹ (ការធ្លាក់ទឹកចិត្តរបស់ ស៊ុហ្ស៊ឹមិយ៉ា ហារុហិ)

រឿងភាគនេះបង្ហាញពីជីវិតសិក្សាដ៏អាថ៌កំបាំងរបស់សិស្សវិទ្យាល័យមួយចំនួនគឺ ស៊ុហ្ស៊ឹមិយ៉ា ហារុហិ និង ក្យុន។ មនុស្សជាច្រើនបានមើលការរាំយ៉ាងលឿនដែលសម្តែងដោយតួអង្គដល់បទបញ្ចប់ គឺបទ «ហារិ ហារ៉ែរិ យ៉ុកៃ(មេឃស្រឡះបើកថ្ងៃ មានសុភមង្គល)» ដែលបានជំរុញឱ្យមនុស្សជាច្រើនសាកល្បងរាំ។ វាក៏បានជំរុញឱ្យមាននិន្នាការនៃការបង្ហោះវីដេអូនៅលើអ៊ីនធឺណិតជាមួយនឹងឃ្លាថា«#odottemita(«អុដុតតិមិតា»ខ្ញុំបានសាកល្បងរាំហើយ)»។ *©2006 Tanigawa Nagaru / Ito Noizi / SOS 団*

## រឿង ហ៊ីរ៉ូហ្គារុ ស្កាយ! ព្រីជីក្យួអា (សំកាងលើវេហា! ស្រស់ស្អាតខ្លាំងណាស់)

វគ្គមួយនៅក្នុងរឿង ព្រីជីក្យួអា ដែលពណ៌នារឿងរ៉ាវនៃតួអង្គសំខាន់ៗបានប្រែកាយទៅជាអ្នកចម្បាំងវេទមន្តព្រីជីក្យួអា ដែលប្រឈមមុខនឹងឧបសគ្គផ្សេងៗ។ ឈុតបញ្ចប់ តួអង្គសំខាន់ៗបានរួមគ្នាសម្តែងក្បាច់រាំដ៏គួរឱ្យស្រឡាញ់ ដែលធ្វើឱ្យក្មេងៗចង់ចូលរួមជាមួយតួអង្គទាំងនោះដែរ។ *©ABC-A / TOEI ANIMATION CO., LTD.*

## រឿង ដូរ៉ាអិម៉ុន (តុក្កតាធ្មាយន្ត)

គំនូរជីវចលដ៏ពេញនិយមបំផុតមួយនៅក្នុងប្រទេសជប៉ុន ដែលបានបង្ហាញខ្លួនដំបូងក្នុងឆ្នាំ១៩៧៩ ហើយមាននៅលើកញ្ចក់ទូរទស្សន៍អស់រយៈពេលជាង៤០ឆ្នាំ ដែលពិពណ៌នាអំពីជីវិតប្រចាំថ្ងៃរបស់ ដូរ៉ាអិម៉ុន ដែលជាធ្មាយន្តពីអនាគត និងក្មេងប្រុសណុប៊ិតា ជាសិស្សសាលាបឋមសិក្សា។ បទចម្រៀងបញ្ចប់មួយបទគឺ «អុដូរិ ដុរិ ដុរ៉ា ដូរ៉ាអេម៉ុន អុនដូ (រាំទៅៗដូរ៉ាអិម៉ុន)» ដែលតួអង្គស្លៀកពាក់យូកាតា(សម្លៀកបំពាក់ប្រពៃណីជប៉ុនសម្រាប់រដូវក្តៅ) និងហាប់ពី(អាវក្រៅបែបប្រពៃណីជប៉ុន) រាំបាំបុនអុដូរី។

*©Fujiko Production / SHOGAKUKAN Inc. / TV Asahi Corporation / SHIN-EI ANIMATION Co., Ltd. / ADK*

ទំព័រទី១៦៖

## ដំណើរកំសាន្តនិម្មិតឆ្លងកាត់ប្រទេសជប៉ុន៖ របាំរបាំងមុខរបស់ប្រទេសជប៉ុន

ផ្កា សត្វ យក្ខ ឬ បិសាច អាទិទេព ឬ ព្រះ គឺជាប្រពៃណីសម្រាប់ប្រជាជនក្នុងប្រទេសជប៉ុនស្លៀកសម្លៀកបំពាក់ដ៏អស្ចារ្យសម្រាប់ការរាំក្នុងពិធីបុណ្យប្រចាំតំបន់។

### ខេត្តហ៊ីរ៉ូស៊ីម៉ា «ហាណាហ្គាសា អុដូរី (របាំមួកផ្កា)»

ខណៈពេលដែលសិល្បៈសម្តែងក្នុងស្រុកជាច្រើនប្រើ«ហាណាហ្គាសា(មួកផ្កា)»ដែលត្រូវបានតុបតែងលម្អដោយផ្កាសិប្បនិម្មិតត្រូវបានប្រើនៅក្នុងពិធីបុណ្យនៅក្រុងគិតាហ៊ីរ៉ូស៊ីម៉ា ខេត្តហ៊ីរ៉ូស៊ីម៉ា គឺស្រស់ស្អាតជាពិសេស ដោយការតុបតែងផ្កាក្រដាសជប៉ុនចងជាប់នឹងបន្ទះឫស្សីព្យួរប្រវែងប្រហែល១.៥ម៉ែត្រ។ អ្នករបាំស្លៀកពាក់យ៉ាងស្រស់ស្អាតធើតឆាយដើរដង្ហែតាមដងផ្លូវក្នុងក្រុង។ *(រូបភាព៖ photolibrary)*

### ខេត្តស៊ីម៉ាណិ «សាហ្គិ ម៉ៃ (របាំកុកស)»

សត្វកុកដែលមានរោមពណ៌សសុទ្ធត្រូវបានគេចាត់ទុកថា ជាបក្សីនាំសំណាងតាំងពីបុរាណកាលមក ក្នុងប្រទេសជប៉ុន។ នៅព្រះវិហារយ៉ាសាកា ក្នុងក្រុងត្ស៊ូវ៉ាណុ ខេត្តស៊ីម៉ាណិ អ្នករបាំស្លៀកពាក់ជាសត្វកុកឈ្មោល និងញី ដែលមានក្បាល និងស្លាបធ្វើពីឈើ ហើយលាតស្លាបត្រដាងចុះឡើង និងគ្រវីរវាំទៅតាមសំឡេងខ្លុយ និងស្គរ។*(រូបភាព៖ photolibrary)*

### ខេត្តគីម៉ាម៉ុតុ «យ៉ាម៉ាហ្គា តូរ៉ូ អុដូរី (របាំចង្កៀងយ៉ាម៉ាហ្គា)»

ចង្កៀងយ៉ាម៉ាហ្គា គឺជាសិប្បកម្មប្រពៃណីរបស់ទីក្រុងយ៉ាម៉ាហ្គា ខេត្តគីម៉ាម៉ុតុ ដែលផលិតចេញពីក្រដាសវ៉ាស៊ិ (ក្រដាសប្រពៃណីជប៉ុន) និងកាវដែលផលិតដោយដៃ មិនប្រើឈើ និងដែកគោលទេ។ រៀងរាល់ឆ្នាំនៅរដូវក្តៅ យើងអាចមើលឃើញ ស្ត្រីប្រហែល១,០០០នាក់បានពាក់ចង្កៀងយ៉ាម៉ាហ្គាពណ៌មាសនៅលើក្បាលរបស់ពួកគេ ហើយរាំតាមបទចម្រៀងប្រពៃណី«យ៉ុហិហុ ប៊ុស៊ិ»។ *(រូបថត៖ PIXTA)*

### ខេត្តក្យូតុ «ហុតុកិ ម៉ៃ (របាំព្រះពុទ្ធ)»

អ្នករបាំស្លៀកពាក់ជាព្រះពុទ្ធ ពាក់របាំងមុខព្រះពុទ្ធ និងក្បាច់រាំដ៏ប្រណិតជាមួយតន្ត្រីបុរាណជប៉ុនដែលមានឈ្មោះថាហ្គាហ្គាគឺ។ របាំនេះត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំ នៅថ្ងៃទី៨ ខែឧសភា នៅវត្តម៉ាត្ស៊ឹណុអុ ដិរ៉ា ក្នុងទីក្រុង ម៉ៃហ្ស៊ឺរ៉ឺ ខេត្តក្យូតុ។

<u>ទំព័រទី១៧៖</u>

## ខេត្តនីហ្គាតា «អុនដិកុ (របាំស្គរបិសាច)»

របាំស្គរបិសាចនេះមាននៅលើកោះសាដុ ខេត្តនីហ្គាតា ជាកន្លែងដែលសិល្បៈសម្តែងរីកចម្រើន។ របាំនេះគេរាំនៅតាមព្រះវិហារ និងតាមផ្ទះប្រជាជន ដើម្បីបួងសួងសូមឱ្យការប្រមូលផលបានល្អ និងសេចក្តីសុខចម្រើនក្នុងគ្រួសារ។ ការសម្តែងដ៏គួរឱ្យរីករាយជាមួយចង្វាក់ស្គរតៃកុ និងការរាំដ៏ទន់ភ្លន់ដែលរួមបញ្ចូលធាតុផ្សំនៃល្ខោនណូ។ វាត្រូវបានសម្តែងប្រហែល១២០កន្លែងនៅលើកោះ ហើយអ្នកទស្សនានឹងរីករាយជាមួយការមើលឃើញនូវភាពខុសគ្នានៃការសម្តែងទាំងនោះ។*(រូបភាព៖ amanaimages)*

## ខេត្តអ៊ីវ៉ាតិ និង ខេត្តមិយ៉ាហ្គិ «ស៊ិស៊ិ អុដូរី (របាំក្តាន់)»

ទម្រង់នៃរបាំប្រែប្រួលទៅតាមតំបន់ ប៉ុន្តែអ្នករបាំជាធម្មតា គឺសម្តែងដោយពាក់ក្បាលជារូបសត្វក្តាន់ ដោយមានបង្គោលឫស្សី «សាសារ៉ា»តុបតែងពីក្រដាសពណ៌ស ដាក់ខ្ពស់ពីលើក្បាលរបស់ពួកគេ ហើយវាយស្គរតៃកុ នៅពេលពួកគេរាំ។ ជំហានរាំ និងក្បាលគ្រវីខ្លាំង សឹងតែសាសារ៉ាប៉ះនឹងដី មើលទៅគួរឱ្យចាប់អារម្មណ៍ខ្លាំងណាស់។ *(រូបភាព៖ photolibrary)*

## ខេត្តយ៉ាម៉ាហ្គាតា «កាសេដូរី (របាំមនុស្សចំបើង)»

យុវជនស្លៀកសម្លៀកបំពាក់ធ្វើពីចំបើងត្បាញ ហៅថា«កេនដាយ» ប្រែក្លាយខ្លួនជា «កាសេដូរី» ជាមនុស្សចំបើង ដើម្បីនាំសាររបស់អាទិទេព ឬ ព្រះ ដោយដើររាំដង្ហែជុំវិញទីក្រុង និងស្រែកថា«កាកកាកកាកា»។ អ្នកស្រុកជះទឹកត្រជាក់ទៅ កាសេដូរី ដើម្បីបួងសួងចៀសផុតពីអគ្គិភ័យ និងសូមឱ្យមានភាពចម្រុងចម្រើនក្នុងការធ្វើអាជីវកម្មរបស់ពួកគេ។ *(រូបភាព៖ ទីក្រុងកាមិណូយ៉ាម៉ា ខេត្តយ៉ាមាហ្គាតា)*

## ខេត្តមិអិ «អ៊ិសិ ដៃកាហ្គ៊ូរ៉ា (របាំតោនៃព្រះវិហារអ៊ិសិ)»

បន្ទាប់ពីបានធ្វើការសម្តែងនៅកន្លែងផ្សេងៗទូទាំងប្រទេសហើយ ក្រុមរបាំអ៊ិសិ ដៃកាហ្គ៊ូរ៉ា កុស្យ៉ា (ក្រុមរបាំតោផ្លូវការ) បានប្រមូលផ្តុំគ្នានៅចុងឆ្នាំដើម្បីសម្តែងរបាំតោព្រះវិហារម៉ាស៊ូដា ដែលជាផ្ទះរបស់ពួកគេក្នុងទីក្រុងគុវ៉ាណា ខេត្តមិអិ។ ទស្សនិកជនមើលឃើញពីទិដ្ឋភាពដ៏ភ្ញាក់ផ្អើល ដែលការសម្តែងដូចទៅនឹងកីឡាកាយសម្ព័ន្ធ ដោយអ្នករាំម្នាក់ពាក់ក្បាលតោ ហើយបង្វិលធត្រយ៉ាងមានលំនឹងនៅលើស្មាសមាជិកសម្តែងជាមួយគ្នា។ *(រូបភាព៖ សមាគមទេសចរណ៍ទីក្រុងគុវ៉ាណា)*

## ខេត្តសៃតាម៉ា «កាវ៉ាហ្គោអិ ម៉ាត្ស៊ុរី បាយ៉ាស៊ិ»

ពិធីបុណ្យមួយដែលបានប្រារព្ធឡើងនៅរដូវស្លឹកឈើជ្រុះនៅក្នុងទីក្រុងកាវ៉ាហ្គោអិ ខេត្តសៃតាម៉ា ដែលគេស្គាល់ថា ជាកន្លែងមានឃ្លាំងចាស់ៗជាជួរ។ អ្នករបាំពាក់របាំងមុខកញ្ជ្រោង (បង្ហាញក្នុងរូបភាព) របាំងមុខតោជាដើម រាំតាមភ្លេងខ្លុយ និងស្គរ នៅលើគ្រែស្នែង«សានស្យ៉ា» ដង្ហែតាមដងផ្លូវក្នុងទីក្រុង។ *(រូបភាព៖ photolibrary)*

ទំព័រទី១៨៖

## រសជាតិជប៉ុន៖ ពេលដែលត្រូវទទួលទាន! មីសូមេន

### មីត្រជាក់ថ្មីៗសម្រាប់គុអាហារនារដូវក្តៅ។

*រូបភាព៖ អារ៉ៃ អាគិកុ*

*កិច្ចសហប្រតិបត្តិការ៖ Ikeri (Senjutei)*

*រូបខាងលើ៖ ព្រះវិហារអុមិវ៉ា នៅទីក្រុងសាគុរ៉ៃ ខេត្តណារ៉ា ដែលចាត់ទុកថាជាកន្លែងកំណើតរបស់មីសូមែន។(រូបភាព៖ ព្រះវិហារអូមិវ៉ា)*

*រូបខាងក្រោម៖ ឈុតមួយពីការសម្តែងរបាំ«មិវ៉ាសូមេន កាកិ អ៊ុតា (ចម្រៀងព្យួរមិវ៉ាសូមេន)»។ ខ្សែអំបោះតំណាងឱ្យមីសូមេនដែលត្រូវបានលាតវែង ហើយស្តើង។ ស្ត្រីក្នុងតំបន់សម្តែងរបាំថ្វាយនៅបរិវេណព្រះវិហារអូមិវ៉ា។*

*រូបខាងឆ្វេង៖ មីសូមេនស្ងួតលក់ជាបាច់។ មីសូមេនដែលមានពណ៌លឿង ឬ បៃតង គឺពណ៌ធ្វើឡើងពីបន្លែ។ រូបភាព៖ PIXTA*

សូមេន គឺជាមីដែលធ្វើពីម្សៅស្រូវសាលី ទឹក និងអំបិល។ ស្តង់ដាមីនេះតម្រូវឱ្យអង្កត់ផ្ចិតរបស់វាគឺ១.៣មីលីម៉ែត្រ ឬ តូចជាងនេះ។ មីសូមេនដែលលក់គឺជាមីស្ងួត មុនពេលទទួលទានត្រូវស្ងោរ និងលាងជម្រះឱ្យបានល្អជាមួយទឹកត្រជាក់ ហើយទទួលទានជាមួយទឹកជ្រលក់ត្រជាក់ដែលធ្វើពីទឹកដាស៊ិ។ មីសូមេនមិនត្រឹមតែមើលទៅត្រជាក់ និងងាយស្រួយទទួលទានទេ ប៉ុន្តែវាថែមទាំងមានរសជាតិឆ្ងាញ់ផងដែរ ដែលធ្វើឱ្យវាក្លាយជាអាហារដ៏អស្ចារ្យមួយសម្រាប់រដូវក្តៅ នៅពេលដែលអាកាសធាតុក្តៅបង្អាក់ចំណង់អាហាររបស់អ្នក។

ដើម្បីធ្វើឱ្យសរសៃមីទន់ និងស្វិត ម្សៅទាំងនោះមិនគ្រាន់តែទាញយ៉ាងសាមញ្ញឱ្យទៅជាខ្សែៗនោះទេ វាត្រូវឆ្លងកាត់ដំណើរការដ៏ស្មុគស្មាញ ដូចជាការរវែសរសៃសូត្រអញ្ចឹង។ ដំបូង ម្សៅស្រូវសាលី ទឹក និងអំបិល ត្រូវបានលាយចូលគ្នាដើម្បីបង្កើតជាដុំម្សៅ។ បន្ទាប់មក មូលវាចេញជារាងតូចវែងៗ ដោយលាបប្រេង ហើយពន្លូតជាខ្សែរមូលតែមួយ។ បន្ទាប់ពីការលាតសន្ទឹង និងទាញវាហើយ ទុកវាឱ្យសម្រាកសិន។ ដំណើរការនេះត្រូវបានធ្វើម្តងហើយម្តងទៀត រហូតដល់ចុងបញ្ចប់វាត្រូវបានរុំជុំវិញដំបងពីរ ហើយលាតសន្ទឹងកាន់តែវែង និងកាន់តែស្តើងជាងមុន។ នៅពេលដែលវាមានប្រវែងប្រហែល២ម៉ែត្រ ត្រូវព្យួរវាឱ្យស្ងួត រួចកាត់ជាប្រវែង១៩សង់ទីម៉ែត្រ។

ណាហ្គាស៊ិ សូមេន គឺជាអាហារប្រពៃណីនៅរដូវក្តៅ ដែលតែងតែធ្វើឡើងនៅខាងក្រៅ ហើយមានរាងស្តើង និងត្រជាក់ដែលមើលទៅគឺជាមីសូមេនដ៏ស្រស់។ របៀបទទួលទានគឺ ទឹក និងមីសូមេន ដាក់ចូលទៅក្នុងប្រឡាយបំពង់ឫស្សីដែលបានពុះពាក់កណ្តាល។ ណាហ្គាស៊ិ សូមេន ពេញនិយមពីសំណាក់ក្មេងៗ ដែលនាំគ្នាប្រកួតប្រជែងចាប់យកមីសូមេនដែលហូរក្នុងប្រឡាយបំពង់ឫស្សីនោះមកទទួលទានយ៉ាងសប្បាយរីករាយ។

នៅរដូវរងា ស៊ុបមីក្តៅៗដែលហៅថា «ន្យូមេន» ក៏ឆ្ងាញ់ពិសារផងដែរ។ ស្ងោរសូមេនឱ្យឆ្អិនហើយ ដាក់ទឹកស៊ុបដាស៊ិ រួចបន្ថែមគ្រឿងផ្សំផ្សេងៗទៀត ដូចជាផ្សិតស៊ិតាកិ បន្លែបៃតង និងស៊ុតជាដើម។

មានការពន្យល់ផ្សេងៗគ្នាអំពីដើមកំណើតរបស់សូមេន ក្នុងនោះមានរឿង«មិវ៉ាសូមេន» គឺជាមីសូមេនប្រចាំតំបន់មិវ៉ា នៃទីក្រុងសាគូរ៉ាអ៊ិ ខេត្តណារ៉ា ដែលមានរឿងនិទានមួយដំណាលថា ប្រហែល១២០០ឆ្នាំមុន កូនប្រុសទីពីររបស់ព្រះចៅអធិការនៃព្រះវិហារអូមិវ៉ា ដែលមានទីតាំងនៅស្រុកមិវ៉ា បានចែកចាយស្រូវសាលីដល់ប្រជាជនដែលរងគ្រោះដោយទុរ្ភិក្សនៅទីនោះ ហើយគេបានយកម្សៅស្រូវសាលីធ្វើជាមីសូមែន ដែលគេនិយាយថា វាជាការបង្កើតមីសូមេនជាលើកដំបូង។

សូម្បីតែសព្វថ្ងៃនេះ ជារៀងរាល់ខែកុម្ភៈ នៅព្រះវិហារអូមិវ៉ា បន្ទាប់ពីធ្វើពិធីទស្សន៍ទាយតម្លៃលក់ដុំនៃមីសូមេនប្រចាំឆ្នាំហើយ ស្ត្រីក្នុងតំបន់បានសម្តែងរបាំមួយឈ្មោះថា«មិវ៉ាសូមេន កាកិ អ៊ុតា(ចម្រៀងព្យួរមិវ៉ាសូមេន)»។ ទាំងបទចម្រៀង និងក្បាច់រាំ បង្ហាញពីភាពសប្បាយរីករាយ និងការលំបាកនៃការធ្វើមីសូមេនក៏ពិតមែន ប៉ុន្តែការរាំមានភាពកក់ក្តៅ និងរីករាយ ធ្វើឱ្យអ្នកទស្សនាមានអារម្មណ៍រំភើបរីករាយ។ មីសូមេន និងរបាំ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធជាមួយប្រវត្តិសាស្ត្រជាយូរមកហើយ ហើយពួកគេនឹងបន្តប្រារព្ធពិធីទាំងនេះនាពេលខាងមុខទៀត។

<u>ទំព័រទី១៩៖</u>

*រូបខាងលើ៖ មីសូមេន គឺជាមុខម្ហូបដ៏ពេញនិយមសម្រាប់រដូវក្តៅ ដែលត្រជាក់ និងងាយទទួលទាន។ មីសូមេន ត្រូវទទួលទានជាមួយទឹកជ្រលក់(រូបភាពនៅក្នុងពែងឈើនៅពីក្រោយមីសូមេន) ដែលធ្វើទឹកមីរីន លាយជាមួយទឹកស៊ីអ៊ីវ និងទឹកដាស៊ិ។*

*រូបស្តាំផ្នែកខាងក្រោម៖ «ន្យូមេន» ជាមួយទឹកស៊ុបដាស៊ិក្តៅៗ គឺជារបៀបទទួលទានមីសូមេនក្នុងរដូវរងា។*

*រូបខាងក្រោម៖ មនុស្សម្នាក់កំពុងចាប់មីសូមេនដោយចង្កឹះពីក្នុងប្រឡាយបំពង់ឫស្សី ដែលអាហារមួយនេះហៅថា «ណាហ្គាស៊ិ សូមេន»*

*រូបភាព៖ PIXTA*

ទំព័រទី២០៖

**ទីក្រុងដែលមានទឹកហូរថ្លាឈ្វង់ និងរបាំប្រពៃណី**

## ដើរកំសាន្តប្រទេសជប៉ុន៖ ហ្គូចូ ហាឈិម៉ាន

នៅក្នុងទីក្រុងដ៏ស្ងប់ស្ងាត់ អមដោយសំឡេងទឹកហូរបន្លឺឡើងដល់ត្រចៀក បាននាំនូវពិធីបុណ្យហ្គូចូអុដូរី ឬ របាំហ្គូចូ ជាពិធីបុណ្យដែលមានការរាំដ៏រស់រវើកជារៀងរាល់រាត្រីនៅរដូវក្តៅ។ ហ្គូចូ ហាឈិម៉ាន ជាគោលដៅដ៏អស្ចារ្យសម្រាប់អ្នកដែលចង់ទទួលបានបទពិសោធន៍ដ៏សម្បូណ៌បែបនៃរបាំប្រពៃណីរបស់ជប៉ុន។

*(រូបភាព៖ Photos: គុរិហារ៉ា អុសាមឺ, PIXTA, photolibrary)*




ទំព័រទី២១៖

*១. ទន្លេយ៉ុស៊ិដា ហូរកាត់កណ្តាលទីក្រុង។*

*២. ផ្លូវដែកណាហ្គារ៉ាហ្គាវ៉ា រត់ឆ្ពោះទៅកាន់ ហ្គូចូ ហាឈិម៉ាន។*

*៣. ប្រាសាទហ្គូចូ ហាឈិម៉ាន គឺជាប្រាសាទសាងសង់ពីឈើដែលចំណាស់ជាងគេនៅក្នុងប្រទេសជប៉ុន។*

*៤. ការរាំនៃពិធីបុណ្យហ្គូចូអុដូរី ឬ របាំហ្គូចូ ត្រូវបានចុះក្នុងបញ្ជីជាបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ ជាទម្រង់មួយនៃហ្វ៊ូរ្យូ អុដូរី។ ©Koji Fukuda*

*៥. ស្បែកជើងហ្គិតា(រូបខាងឆ្វេង ផ្តល់ដោយ៖ហ្គូចូ ម៉ុគុរិ) និងកន្សែងតិនុហ្គុយ(រូបភាពផ្តល់ដោយនាយកដ្ឋានពាណិជ្ជកម្ម ឧស្សាហកម្ម និងទេសចរណ៍ ទីក្រុងហ្គូចូ ផ្នែកទេសចរណ៍) គឺជាវត្ថុសំខាន់សម្រាប់ចូលរួមក្នុងពិធីបុណ្យហ្គូចូ អុដូរី។*

*៦. អ្នករបាំមកពីសាលរបាំហ្គុចូហាឈិម៉ាន បង្ហាញនូវរបាំ «កាវ៉ាសាគិ»មួយក្នុងចំណោម ហ្គុចូ អុដូរី ចំនួនដប់។*

<u>ទំព័រទី២២៖</u>

*៧. អំឡុងពេលរាំនាពេលរាត្រី នៅតាមដងផ្លូវពោរពេញទៅដោយមនុស្សម្នាត្រៀមខ្លួនចូលរួមរាំយ៉ាងរីករាយ។ ©សហព័ន្ធទេសចរណ៍ទីក្រុងហ្គុចូ*

*៨. ត្រីកយ ឬ ត្រីគល់រាំង និងត្រីទន្លេផ្សេងទៀតហែលក្នុងប្រឡាយ អិហ្គាវ៉ា កុមិឈិ ដែលជាផ្លូវទឹកហូរនៅខាងក្រោយផ្ទះប្រជាជនជន។*

*៩. ធុងទឹក មិហ្សឹប៊ុណិ ដែលមានថ្នាក់ជាន់ខាងលើត្រូវបានប្រើសម្រាប់ជាទឹកទទួលទាន និងថ្នាក់ជាន់ខាងក្រោមប្រើសម្រាប់ការលាងសម្អាតបន្លែបង្កាជាដើម។ ©សហព័ន្ធទេសចរណ៍ទីក្រុងហ្គុចូ*

*១០. នៅហាងជ្រលក់ពណ៌ក្រណាត់ វ៉ាតាណាបិ (Watanabe Dyehouse)ការជ្រលក់ពណ៌អៃ(ពណ៌ទឹកប៊ិច) នៅតាមប្រឡាយទឹក គឺជាផ្នែកមួយនៃបច្ចេកទេសជ្រលក់ពណ៌របស់ ហ្គុចូ ហុនហ្សូម៉ិ បែបប្រពៃណីដែលបន្តដល់អ្នកជំនាន់ក្រោយ។*

*១១. រូបត្រីគល់រាំង ឬ កយណុបុរិ ត្រូវបានត្រាំនៅក្នុងទន្លេកុដារ៉ា នៅរដូវរងា ដែលជាទំនៀមទម្លាប់មួយហៅថា «កយណុបុរិ ណុ កានហ្សារ៉ាស៊ិ»។ (រូបភាពផ្តល់ដោយ ហាងជ្រលក់ពណ៌វ៉ាតាណាបិ "Watanabe Dyehouse")*

ប្រសិនបើអ្នកជិះរថភ្លើងពីទីក្រុងណាហ្គោយ៉ា ខេត្តអៃឈិ ដែលជាទីក្រុងធំបំផុតនៅក្នុងតំបន់ជូប៊ូ ធ្វើដំណើរទៅភាគខាងជើងប្រហែល២ម៉ោង អ្នកនឹងទៅដល់ ហ្គុចូ ហាឈិម៉ាន ក្នុងខេត្តហ្គីហ្វូ។ ហ្គុចូ ហាឈិម៉ាន ធ្លាប់ជាកន្លែងសម្រាកសម្រាប់អ្នកហែរក្បួនធម្មយាត្រាទៅកាន់ភ្នំដ៏ពិសិដ្ឋ ហាគុសាន ហើយចាប់តាំងពីចុងសតវត្សរ៍ទី១៦ នៅពេលដែល ប្រាសាទ ហ្គុចូ ហាឈិម៉ាន ត្រូវបានសាងសង់ វាបានអភិវឌ្ឍទៅជាទីក្រុងប្រាសាទដែលមានអ្នកជំនួញជាច្រើនចេញចូល។ តំបន់នេះហ៊ុំព័ទ្ធដោយភ្នំ និងសំឡេងទឹកហូរនៃទន្លេ យ៉ុស៊ិដា និងទន្លេកុដារ៉ា ដែលហូរកាត់ទីក្រុងនេះបន្លឺឡើងយ៉ាងស្រទន់ ធ្វើឱ្យចិត្ត និងគំនិតអ្នកទស្សនាមានភាពធូរស្រាល ទាំងពេលបច្ចុប្បន្ន និងកាលពីពេលអតីតកាល។

នៅរដូវក្តៅ ទីក្រុងដ៏ស្ងប់ស្ងាត់មួយនេះ មានការផ្លាស់ប្តូរទាំងស្រុងជាមួយនឹងការមកដល់នៃពិធីបុណ្យហ្គុចូអុដូរី។ ពិធីបុណ្យហ្គុចូអុដូរី ដែលមានប្រវត្តិប្រហែល៤០០ឆ្នាំ ត្រូវបានប្រារព្ធឡើងនៅទីតាំងផ្សេងៗគ្នាទូទាំងទីក្រុងរយៈពេល៣១ថ្ងៃ ចាប់ពីខែកក្កដាដល់ខែកញ្ញា ហើយក្នុងទីក្រុងទាំងមូលពីអ្នកស្រុកក្នុងតំបន់ដល់អ្នកក្រៅតំបន់ គឺបន្តរាំជាមួយគ្នា។ ការរាំដែលលេចធ្លោជាងគេនោះ គឺការរាំពេញមួយយប់ដែលធ្វើឡើងចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៦ ខែសីហា។ អំឡុងពេលរាំពេញមួយយប់ ចាប់ពីម៉ោង៨យប់ រហូតដល់ ម៉ោង៥ព្រឹក គឺបានទាក់ទាញអ្នកទស្សនារាប់ម៉ឺននាក់ ហើយទីក្រុងពោរពេញដោយភាពរីករាយយ៉ាងកក់ក្តៅ។

នៅសារមន្ទីរ ហ្គុចូ ហាឈិម៉ាន ហាគូរ៉ានកាន ផ្តល់ជូននូវការបង្រៀនរបាំដោយគ្រូបង្ហាត់ ទោះបីជាមិនស្ថិតនៅក្នុងវគ្គសិក្សាក៏ដោយ គឺដើម្បីឱ្យអ្នកទាំងអស់គ្នាទទួលបានបទពិសោធន៍នៃការរាំ។ ទិដ្ឋភាព និងសំឡេងនៃអ្នកសម្តែង និងរាំជាជំហានៗជាមួយនឹងតន្ត្រីប្រពៃណី ការទះដៃជាមួយគ្នា ហើយពេលខ្លះនៅពេលឮស្បែកជើងហ្គិតាឈូសនឹងដី គឺធ្វើឱ្យអ្នកទស្សនាចាប់ផ្តើមរាំជាមួយគ្នា។

<u>ទំព័រទី២៣៖</u>

*១២. ត្រីអាយឺ ត្រូវបានគេស្គាល់ថាជាត្រីសាច់ផ្អែម ហើយនៅពេលដែលអាំងអំបិលយើងនឹងរីករាយជាមួយនឹងក្លិនឈ្ងុយឆ្ងាញ់របស់វា។ © សហព័ន្ធទេសចរណ៍ទីក្រុងហ្គុចូ*

*១៣. គេសជ្ជៈ «សាយដឺ» ដែលមានជាតិកាបូន និងរសជាតិស្រស់ស្រាយ ត្រូវបានផលិតដោយទឹកធម្មជាតិពីហ្គុចូ ហាឈិម៉ាន។*

*១៤/១៥. បង្អែមប៉ាហ្វេត មាននៅហាងកាហ្វេ ម៉ាតចា សូហ្គិអាន នៅក្នុងផ្ទះបុរាណកុមីនកា ដែលត្រូវបានកែលម្អឡើងវិញ។ ហ្គុចូ អុដូរី ត្រូវបានបង្ហាញឱ្យឃើញនៅលើសិល្បៈម៉ាតចា(តែបៃតង)។*

*១៦. សិក្ខាសាលាក្នុងស្រុកដែលអនុញ្ញាតឱ្យអ្នកទស្សនាសាកល្បងក្នុងការពិសោធន៍អាហារដោយខ្លួនឯង។ (រូបភាពផ្តល់ដោយ៖ Sample Kobo)*

*១៧. គំរូអាហារនៃប៉ាស្តាជាមួយសម។*

ប្រសិនបើអ្នកដើរជុំវិញទីក្រុង អ្នកនឹងឃើញថាមានប្រឡាយទឹកពេញទីក្រុង រួមទាំងអ៊ីហ្គាវ៉ា កុមិឈិ(ប្រឡាយទឹកតូចៗនៅក្រោយផ្ទះប្រជាជន)ផងដែរ។ ប្រឡាយទឹកទាំងនេះ ត្រូវបានសាងសង់ឡើងសម្រាប់គោលបំណងជួយទប់ស្កាត់អគ្គិភ័យបន្ទាប់ពីមានហេតុការភ្លើងឆេះដ៏សន្ធោសន្ធៅក្នុងសតវត្សរ៍ទី១៧ ហើយប្រឡាយទឹកទាំងនេះនៅតែជាផ្នែកដ៏សំខាន់មិនអាចខ្វះបាននៅក្នុងទីក្រុងនេះ។ នៅតាមប្រឡាយទឹកទាំងនោះ មាន«មិហ្ស៊ឺហ្វ៊ុណិ(ន័យត្រង់គឺ ទូកទឹក)» ដែលជាធុង ឬ អាងដែលពោរពេញទៅដោយទឹកហូរចេញពីភ្នំ ដែលប្រជាជនប្រើទឹកនោះសម្រាប់ទទួលទាន និងលាងបន្លែបង្កាជាដើម។

ផ្លូវទឹកក៏មានសារៈសំខាន់ផងដែរសម្រាប់សិប្បកម្មប្រពៃណីដែលហៅថា ហ្គុចូ ហុនហ្សុម៉ិ។ នៅពេលដែលដាក់ក្រណាត់ជ្រលក់ពណ៌ទៅក្នុងទឹកដែលកំពុងហូរ ថ្នាំជ្រលក់ពណ៌អែ ឬ ពណ៌ទឹកប៊ិច បង្កើតបានពណ៌កាន់តែរស់រវើក និងជួយរឹតបន្តឹងសាច់ក្រណាត់បានល្អផងដែរ។ ក្នុងរដូវរងា ទំនៀមទម្លាប់មួយហៅថា «កយណុបុរិ ណុ កានហ្សារ៉ាស៊ិ» ត្រូវបានធ្វើឡើងនៅក្នុងទន្លេដែលក្នុងនោះ កយណុបុរិ (ក្រណាត់វែងៗរាងដូចត្រីគល់រាំង)ដែលតុបតែងដើម្បីដាក់បង្ហាញនៅក្នុងការប្រារព្ធពិធីអបអរសាទរនៃការលូតលាស់របស់ក្មេងប្រុស ត្រូវបានត្រាំនៅក្នុងទន្លេដ៏ថ្លាឈ្វង់ដែលកំពុងហូរ។ ការមើលឃើញនៃពណ៌ចម្រុះ ភ្លឺចិញ្ចាចអណ្តែតលើផ្ទៃទឹក គឺជាទិដ្ឋភាពប្លែកតែមួយគត់នៃរដូវរងានៅហ្គុចូ ហាឈិម៉ាន។

អ្នកទស្សនាក៏អាចរីករាយជាមួយត្រីអាយឺផ្អែមអាំងអំបិល ជាអាហារដ៏ឈ្ងុយឆ្ងាញ់ក្នុងស្រុក ដែលលក់នៅតាមតូបលក់អាហារនៅមាត់ទឹក ខណៈពេលដែលបានឮនូវសំឡេងទឹកហូរ ឬ អាចសម្រាកនៅហាងកាហ្វេដែលមានបង្អែមនៅក្នុងផ្ទះបុរាណ កុមីនកាដែលត្រូវបានកែលម្អឡើងវិញ។ បទពិសោធន៍ដ៏ពិសេសនឹងក្លាយជាការចងចាំមិនអាចបំភ្លេចបានមួយទៀត គឺប្រហែលជាអ្នកកំពុងឈានជើងចូលទស្សនារោងសិប្បកម្មផលិតអាហារគំរូ ដែលអ្នកអាចសាកល្បងក្នុងការធ្វើគំរូអាហារដែលមានដើមកំណើតនៅហ្គុចូ ហាឈិម៉ាន។

ការរាំដ៏រស់រវើក និងការដើរលំហែតាមមាត់ទឹក នៅ ហ្គូចូ ហាឈិម៉ាន ដែលមានទាំងភាពអ៊ូអរ និងស្ងប់ស្ងាត់ខុសស្រឡះពីគ្នា គឺបានផ្តល់នូវភាពទាក់ទាញជាច្រើនដល់អ្នកទស្សនាវីកែរាយពិតប្រាកដ។

***ផែនទីតំបន់ហ្គូចូ ហាឈិម៉ាន(សូមមើលរូប)***

*១. ប្រាសាទហ្គូចូ ហាឈិម៉ាន*
*២. សារមន្ទីរ ហ្គូចូ ហាឈិម៉ាន ហាគុរ៉ានកាន*
*៣. អ៊ិហ្គាវ៉ា កុមិឈិ (ផ្លូវប្រឡាយទឹកតូចៗនៅក្រោយផ្ទះប្រជាជន)*
*៤. ហាងជ្រលក់ក្រណាត់ វ៉ាតាណាបិ (Watanabe Dyehouse)*
*៥. ហាងកាហ្វេ សុហ្គិ អាន*
*៦. ហាងលក់វត្ថុអនុស្សាវរីយ៍ដែលអាចធ្វើវត្ថុដោយខ្លួនឯងបាន (Sample Kobo)*

*. មធ្យោបាយធ្វើដំណើរ៖*
*ពីស្ថានីយ៍ណាហ្គោយ៉ា ទៅកាន់ស្ថានីយ៍ហ្គូចូ ហាឈិម៉ាន គឺប្រហែល ២ម៉ោង តាម ខ្សែរថភ្លើង JR តូកៃ្យ និងរថភ្លើង ណាហ្គារ៉ាហ្គាវ៉ា។*
*. ទំនាក់ទំនងព័ត៌មាន សូមចូលទៅកាន់គេហទំព័រផ្លូវការរបស់សហព័ន្ធទេសចរណ៍ទីក្រុងហ្គូចូ TABITABI Gujo*
*https://tabitabigujo.com/*

ទំព័រទី២៤៖ **វត្ថុអនុស្សាវរីយ៍របស់ជប៉ុន៖**

## បន្ថែមភាពទាក់ទាញដល់សម្លៀកបំពាក់របស់អ្នក

## កានហ្សាស៊ិ

*កានហ្សាស៊ិ គឺជាគ្រឿងតុបតែងសក់ដែលមានការរចនាផ្សេងៗដូចជានៅក្នុងរូបភាព (១, ៣) គឺផ្កាធ្វើពីលោហៈ ព្រមជាមួយការតុបតែងដោយគុជខ្យង,(២) ផ្កាដែលធ្វើពីក្រណាត់សូត្រ។ (៤)ម៉ូដផ្កាអាជិសៃងាយស្រួលបញ្ចូលទៅក្នុងដង្កៀបម៉ូដសក់។*

*(៥) គ្រឿងតុបតែងសក់ដ៏ឆើតឆាយ មានការរចនាជាច្រើនប្រភេទ ដូចជាធ្វើពីម្រ័ក្សណ៍ខ្ចុក និងមាសដែលមានរូបសត្វស្លាប និង(៦) ធ្វើពីក្រណាត់សូត្រ រចនាជារាងផ្កាសាគូរ៉ា។*

*(៧)កានហ្សាស៊ិ មានរំយោល ដែលផ្តល់ភាពរំភើបដល់អ្នកពាក់នៅពេលដើរមួយជំហានៗ ដោយការរង្គើតិចៗរបស់វា ។*

កានហ្សាស៊ិ គឺជាគ្រឿងតុបតែងសក់បែបប្រពៃណីដែលស្ត្រីជប៉ុននិយមប្រើ។ សូម្បីតែសព្វថ្ងៃនេះ ពេលស្លៀកសម្លៀកបំពាក់បែបប្រពៃណីជប៉ុនគីម៉ូណូ ក្នុងឱកាសកម្មវិធីដូចជា ការរាំរបាំប្រពៃណីជប៉ុន និហុនប៊ូយ៉ូ ឬ បុនអុដូរីជាដើម អ្នករបាំតែងតែបន្ថែមនូវកានហ្សាស៊ិ ដើម្បីតុបតែងលើសក់ កុំឱ្យមានកូនសក់ធ្លាក់មកប៉ះនឹងកអាវ។

គ្រឿងតុបតែងសក់ត្រូវបានគេនិយាយថា មានតាំងពីសតវត្សរ៍ទី៨ ប៉ុន្តែក្រោយមក ម៉ូដសក់របស់ស្ត្រីក្លាយទៅជាម៉ូដទាន់សម័យដោយទម្លាក់សក់ ហើយកានហ្សាស៊ិ ត្រូវបានឈប់ប្រើជាច្រើនសតវត្សរ៍។ បន្ទាប់មកគ្រឿងតុបតែងសក់ទាំងនេះបានក្លាយជាការពេញនិយមយ៉ាងទូលំទូលាយពីសាធារណជនទូទៅ នៅសម័យអេដូ (១៦០៣-១៨៦៨) ដែលស្ត្រីចងសក់ដោយបន្ថែមជាមួយកានហ្សាស៊ិ បានក្លាយជាការពេញនិយមក្នុងការធ្វើម៉ូដសក់ដែលមិនអាចខ្វះបាន។ កានហ្សាស៊ិ ត្រូវបានបង្កើតឡើងពីមួយទៅមួយ ដោយច្នៃយ៉ាងប្រណិតជារាងផ្កា និងសត្វស្លាប ដែលធ្វើពីលោហៈ ឬ ឈើ ក្រណាត់ ក្រដាស ជាដើម។

សព្វថ្ងៃនេះ មានកានហ្សាស៊ិ ដែលមានតម្លៃថោកផលិតពីផ្លាស្ទិក និងកញ្ចក់ ដែលអាចប្រើប្រាស់បាន។ ដូច្នេះអ្នកមានជម្រើសច្រើនក្នុងការប្រើប្រាស់គ្រឿងបែបបុរាណទាំងនេះដោយមិនត្រូវបានកំណត់ចំពោះថ្ងៃពិសេស ឬ ឱកាសពិសេសនោះទេ ប៉ុន្តែវាអាចជាគ្រឿងតុបតែងម៉ូដសក់ប្រចាំថ្ងៃផងដែរ។

*រូបភាពផ្តល់ដោយ៖ កាហ្សូ៉ា សិអ៊ិ*

*ទស្សនាវដ្តី "និប៉ុនិកា" លេខ៣៥*
*បោះពុម្ពផ្សាយដោយក្រសួងការបរទេសជប៉ុន*
*២-២-១ កាស៊ឹមិហ្គាសិគិ សង្កាត់ជិយ៉ូដា ទីក្រុងតូក្យូ ១០០-៨៩១៩ ប្រទេសជប៉ុន*
*គេហទំព័រផ្លូវការរបស់ក្រសួង https://www.mofa.go.jp/*
*គេហទំព័រដែលផ្តល់ព័ត៌មានអំពីជប៉ុន https://web-japan.org/*